# អ្នកជំនាញពីររូបធ្វើកសិណសាក្សី ម្នាក់មិនសូវនិយាយស្តី

ដោយ ឡូរ៉ា ម៉ាកដូណល់
ថ្ងៃទី២៦ ខសភា ឆ្នាំ២០០៩
ប្រែសម្រួលដោយ ទែន សុខស្រីនិត

## ជម្លោះប្រដាប់អាវុធរវាងវៀតណាម និងកម្ពុជា

នៅក្នុងសាលសាធារណៈរបស់អង្គសវនាការមានសភាពអូរអរ ដោយមានសិស្សនិស្សិតកម្ពុជា និងអ្នកភូមិជាច្រើនបានចូលរួមតាមដានដំណើរការសវនាការនាពេលព្រឹកនេះខណៈពេលដែល ណាយ៉ាន់ ចាន់ដា ដែលជាអតីតអ្នកឆ្លើយឆ្លងព័ត៌មានរបស់ទស្សនាវដ្តីសេដ្ឋកិច្ចចុងបូព៌ា និងជាអ្នកនិពន្ធសៀវភៅ "សត្រូវបងប្អូនឯង" និង "សង្គ្រាមបន្ទាប់ពីសង្គ្រាម" បានបញ្ចប់កសិណសាក្សីរបស់លោកស្តីពីជម្លោះប្រដាប់អាវុធរវាងវៀតណាម និងកម្ពុជា ។

ណាយ៉ាន់ ចាន់ដា បានរៀបរាប់ពីបទពិសោធន៍របស់លោក នៅឯជំរុំភៀសខ្លួនតាមព្រំប្រទល់វៀតណាម ។ ក្រោយពីបានរត់គេចខ្លួនចេញពីប្រទេសកម្ពុជាដោយស្ម័គ្រចិត្តជាមួយនឹងទាហានវៀតណាម ណាយ៉ាន់ ចាន់ដា បានរាយរាប់ថា អ្នករត់ភៀសខ្លួនកម្ពុជាទាំងអស់រស់នៅដោយភាពភ័យខ្លាច ប៉ុន្តែក៏នៅមានសង្ឃឹមថានឹងបានវិលត្រឡប់មកកាន់ប្រទេសកំណើតរបស់ខ្លួនវិញ នៅពេលដែលកម្ពុជាត្រូវបាន«រំដោះ»ដោយកងទ័ពវៀតណាម ។ ណាយ៉ាន់ ចាន់ដា បានរៀបរាប់អំពីការរៀបចំនៅក្នុងតំបន់ដែលបណ្តាលមកពីការបញ្ជូនជនភៀសខ្លួនកម្ពុជា ដែលមកលក់ដូរបសុសត្វនៅតាមមូលដ្ឋាននីមួយៗឲ្យត្រឡប់ទៅកាន់ប្រទេសកម្ពុជាវិញទាំងបង្ខំ ។ ដោយទទួលស្គាល់ថាខ្លួនលោកខ្វះខាតនូវការយល់ដឹងដោយផ្ទាល់ ណាយ៉ាន់ ចាន់ដា បានបញ្ចេញយោបល់ថា កងទ័ពវៀតណាមដែលបានបញ្ជូនជនភៀសខ្លួនកម្ពុជាទាំងអស់ត្រឡប់ទៅកម្ពុជាវិញត្រូវបានសង្ស័យថា ជនភៀសខ្លួនទាំងនោះនឹងត្រូវសម្លាប់ចោលប្រសិនបើពួកគេត្រឡប់មកវិញ ។

ការ សាវុត្ថ មេធាវីការពារក្តីជាតិ បានចោទសួរតែមួយសំណួរប៉ុណ្ណោះបន្ទាប់ពីបាននិយាយថាជម្លោះប្រដាប់អាវុធនេះគឺកើតឡើងរវាងប្រទេសទាំងពីរ ហើយវាមិនមានអ្វីជាប់ពាក់ព័ន្ធនឹងជនត្រូវ

ចោទ កាំង ហ្គេកអ៊ាវ (ឌុច) នោះទេ។ ហ្រ្វង់ស្វ័រ រូ មេធាវីការពារក្ដីអន្ដរជាតិបានស្នើសុំឲ្យ ឌុច ទទួលបានឱកាសដើម្បីធ្វើការឆ្លើយតបទៅនឹងកសិណសាក្សី ណាយ៉ាន់ ចាន់ដា ។ នៅក្នុងការនិយាយដ៏យូរនេះ ឌុច ទំនងជាសម្លឹងមើលមក ណាយ៉ាន់ ចាន់ដា ខណៈពេលដែលលោកសម្លឹងមើលទិសដៅផ្សេង។ ឌុច បានកោតសរសើរចំពោះសមិទ្ធផលរបស់ ណាយ៉ាន់ ចាន់ដា ក្នុងការរៀបរាប់ពីព្រឹត្តិការណ៍សំខាន់ៗ និងនាំយក«គោលគំនិតសំខាន់ៗ»អំពីប្រទេសវៀតណាមដែលបន្ទាប់មក ឌុច បានធ្វើការគូសបញ្ជាក់ពីព្រឹត្តិការណ៍ទាំងនេះ។ ជាពិសេស ឌុច បាននិយាយថា វៀតណាមចង់ឲ្យបក្សកុម្មុយនីស្ដកម្ពុជាដើរតាមមាគ៌ារបស់ខ្លួន ហើយប្រសិនបើវៀតណាមមិនអាចសម្រេចគោលដៅនេះទេនោះ វៀតណាមមានគម្រោងអនុញ្ញាតឲ្យប្រជាជនខ្មែរធ្វើការវាយប្រហារផ្ដួលរំលំ ប៉ុល ពត។ ប្រសិនបើគម្រោងនេះនៅតែទទួលបរាជ័យទៀតនោះ វៀតណាមនឹងធ្វើការវាយប្រហារកម្ពុជាពីផ្នែកខាងក្រៅវិញម្ដង។ ឌុច បានទទួលស្គាល់ថា ជម្លោះ«ដ៏យូរនិងអូសបន្លាយ»រវាងកម្ពុជានិងវៀតណាមនេះ បានបង្កឲ្យមានការតស៊ូបង្ហូរឈាមរវាងប្រជាជនស៊ីវិលរបស់ប្រទេសទាំងពីរ។ ឌុច ក៏បាននិយាយបន្ថែមថា ប៉ុល ពល មិនមែនជា«អ្នកស្នេហាជាតិដ៏អស្ចារ្យម្នាក់»នោះទេ ប៉ុន្ដែផ្ទុយទៅវិញ គឺជាឃាតករសម្លាប់ប្រជាជនខ្លួនឯងជាងមួយលាននាក់។ នៅក្នុងចំនួនមនុស្សស្លាប់ដ៏ច្រើននោះ ឌុច បាននិយាយថា ដៃរបស់ខ្លួនគឺប្រលាក់សុទ្ធតែឈាមរបស់មនុស្សចំនួន១២.៣៨០នាក់ ដែលត្រូវបានសម្លាប់នៅគុកទួលស្លែង ដែលត្រូវបានស្គាល់ថា ជាមន្ទីរស-២១ ។

បន្ទាប់ពីការគូសបញ្ជាក់របស់ ឌុច, ហ្រ្វង់ស្វ័រ រូ បានធ្វើការកោតសរសើរ ណាយ៉ាន់ ចាន់ដា ពីសារសំខាន់នៃកសិណសាក្សីរបស់លោក។ ហ្រ្វង់ស្វ័រ រូ បានពន្យល់ថា ព្រះរាជអាជ្ញាព្យាយាមបកស្រាយថាសង្គ្រាមរវាងវៀតណាមនិងកម្ពុជាបានចាប់ផ្ដើមតាំងពីខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ដើម្បីឲ្យ ឌុច អាចត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មសង្គ្រាម ដោយមានជាប់ពាក់ព័ន្ធនឹងអ្នកទោសជនជាតិវៀតណាម ដែលត្រូវបានបញ្ជូនមកកាន់មន្ទីរស-២១ ក្នុងអំឡុងពេលសង្គ្រាមនោះ។ ដោយធ្វើការកត់សម្គាល់ឃើញថា ឌុច បានធ្វើការទទួលស្គាល់ការដឹងឮពីជម្លោះនេះដូចជម្លោះកាលពីខែធ្នូ ឆ្នាំ១៩៧៧ និងដោយបានរំលឹកពីកសិណសាក្សី ណាយ៉ាន់ ចាន់ដា កាលពីម្សិលមិញដែលលើកឡើងថា ការវាយប្រហារតបតរបស់វៀតណាមបានបន្ដមកដល់ចុងឆ្នាំ១៩៧៧ ហ្រ្វង់ស្វ័រ រូ បានស្នើសុំឲ្យ ណាយ៉ាន់ ចាន់ដា ធ្វើការពន្យល់ពីទំហំនៃជម្លោះនេះឲ្យមានលក្ខណៈតូចជាងនេះ។ ណាយ៉ាន់ ចាន់ដា បានពន្យល់ថា លោកមិនមែនជាមេធាវីនោះទេ ហើយលោកក៏មិនបានដឹងថាតើសង្គ្រាមត្រូវតែប្រកាសដើម្បីឲ្យ«សង្គ្រាម»នោះកើតឡើងឬយ៉ាងណានោះទេ។ យ៉ាងណាមិញ

ណាយ៉ាន់ ចាន់ដា បានទទួលស្គាល់ថា ប្រសិនបើសង្គ្រាមអាចកើតឡើងដោយមិនចាំបាច់មានការប្រកាស នោះសង្គ្រាមនឹងបានចាប់ផ្ដើមពីឆ្នាំ១៩៧៥ ។ លោកបានបន្តទៀតថា ប្រសិនបើសង្គ្រាមទាមទារឲ្យមានការប្រកាស នោះសង្គ្រាមនេះនឹងបានចាប់ផ្ដើមនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ ស្របពេលដែលទំនាក់ទំនងការទូតរវាងប្រទេសវៀតណាមនិងកម្ពុជាកំពុងតែមានស្ថានភាពតានតឹង ។ ហ្វ្រង់ស៊័រ រូ ហាក់បីដូចជាពេញចិត្តចំពោះការឆ្លើយតបរបស់ ណាយ៉ាន់ ចាន់ដា ។

## កសិណសាក្សីដ៏ជំនាញដោយ«មិនសូវមានភាពជឿជាក់»

បន្ទាប់ពីការសម្រាកអាហារថ្ងៃត្រង់មកអង្គជំនុំជម្រះបានកោះហៅសាក្សីដ៏ជំនាញ ក្រេក អេតឆេសាន់សារជាថ្មីម្ដងទៀត ដើម្បីពិភាក្សាពីការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរស-២១ ។ វាទំនងជាថា រាល់ពេលដែល ក្រេក អេតឆេសាន់ ចូលដល់បន្ទប់សវនាការ បញ្ហានីតិវិធីតែងតែកើតមានឡើងរហូត ។ ក្នុងអំឡុងរយៈពេលបីម៉ោងសម្រាប់ការធ្វើកសិណសាក្សីនៅថ្ងៃនេះលោកមានឱកាសឆ្លើយតបនឹងសំណួរតែពីរគត់ ។ ក្រេក អេតឆេសាន់ បានធ្វើកសិណសាក្សីថា ក្នុងសមាសភាពជាអ្នកគ្រប់គ្រងមន្ទីរស-២១ ឌុច បានពិនិត្យមើលចម្លើយសារភាព និងរៀបចំបញ្ជីឈ្មោះមនុស្សដែលត្រូវធ្វើការបោសសម្អាត ។ បញ្ជីឈ្មោះមនុស្សទាំងនោះ ត្រូវបានបញ្ជូនទៅឲ្យថ្នាក់លើដើម្បីធ្វើការពិចារណា និងចេញបញ្ជាឲ្យមានការសហការពីថ្នាក់ក្រោមក្នុងការបោសសម្អាត ។

បញ្ហាទាក់ទិននឹងការអធិប្បាយ និងការបកប្រែបានកើតមានឡើង ខណៈពេលដែល អាឡិចសាន់ឌឺ បើត សហព្រះរាជអាជ្ញាអន្តរជាតិបានព្យាយាមស្វែងរកប្រតិកម្មរបស់ ក្រេក អេតឆេសាន់ ចំពោះអត្ថបទពីរទំព័រទាក់ទិននឹងការប្រជុំរបស់ខ្មែរក្រហមដែលមានរយៈពេលពីរនាទី ។ បើទោះបីជាស្ថានភាពដែលបានរៀបរាប់ខាងក្រោមនេះមិនមានសារសំខាន់យ៉ាងណាក៏ដោយ ក៏វាប្រហែលជានឹងបង្ហាញពីបញ្ហាទាក់ទិននឹងការបកស្រាយ និងការបកប្រែដែលជាញឹកញាប់បង្កឲ្យមានភាពស្មុគស្មាញ និងពន្យារដំណើរការនីតិវិធីរបស់តុលាការ ។ សហព្រះរាជអាជ្ញា អាឡិចសាន់ឌឺ បើត និង ក្រេក អេតឆេសាន់គឺសុទ្ធតែជាអ្នកនិយាយភាសាអង់គ្លេសតាំងពីកំណើត ដោយមានឯកសារដែលជាប់ពាក់ព័ន្ធជាភាសាអង់គ្លេសនៅចំពោះមុខរបស់គេផងដែរ ។ ដោយសារតែឯកសារដើមជាភាសាខ្មែរ និងដោយមានការទទូចសុំពី ហ្វ្រង់ស្វ័រ រូ មេធាវីការពារក្ដី ឯកសារនេះត្រូវបានអានជាភាសាខ្មែរនៅក្នុងបន្ទប់សវនាការដោយបុគ្គលិកតុលាការដែលជាអ្នកនិយាយភាសាខ្មែរ ។ ការអានជាភាសាខ្មែរនោះត្រូវបានបកប្រែ

ភ្លាមៗទៅជាភាសាអង់គ្លេស ហើយបន្ទាប់មកទៀត ការបកប្រែជាភាសាអង់គ្លេសនេះត្រូវបានបកប្រែជាភាសាបារាំង។ ដោយសារតែមានការយល់ច្រឡំខ្លះៗ ឯកសារនេះត្រូវបានអានជាច្រើនសារ។ ហ្វ្រង់ស៊័រ រូ ដែលជាអ្នកនិយាយភាសាបារាំង ស្ដាប់ការបកស្រាយជាភាសាបារាំង ស្របពេលដែលកំពុងតែអានឯកសារជាភាសាបារាំងស្ដីពីឯកសារ ដែលកាលពីមុនត្រូវបានបកប្រែដោយបុគ្គលិករបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ហ្វ្រង់ស៊័រ រូ ក្រោកឈរប្រកាសពីភាពមិនស្របគ្នារវាងការអានជាភាសាបារាំង និងឯកសារដែលសរសេរជាភាសាបារាំង។ ដោយបញ្ចេញចំណាប់អារម្មណ៍ទាក់ទិននឹងបញ្ហានេះ ហ្វ្រង់ស៊័រ រូ អាចបញ្ចប់ភាពយល់ច្រឡំនេះបាន នៅពេលដែលមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ដែលជាអ្នកនិយាយភាសាខ្មែរពីកំណើតអានឯកសារនោះ។ ឌុច បានផ្ដល់ជាមតិយោបល់ជាភាសាខ្មែរពីអត្ថន័យរបស់ឯកសារនោះអស់រយៈពេលប៉ុន្មាននាទីដែរ។ ចៅក្រម ឡាវែន់ សួរសំណួរបញ្ជាក់ពីរ-បីទៅកាន់ ឌុច ជាភាសាបារាំង។ សហព្រះរាជអាជ្ញា អាឡិចសាន់ឌ្រឺ បេ៊ត អះអាងថា ឌុច មិនមែនជាអ្នកបកប្រែដ៏ជំនាញនោះទេ ហើយ ឌុច នឹងផ្ដល់ឱកាសឲ្យមានមតិយោបល់លើឯកសារនេះនាពេលក្រោយ។ សហព្រះរាជអាជ្ញាគូសបញ្ជាក់ថា ឯកសារដើមជាភាសាខ្មែរគួរតែត្រូវបានគោរពតាម។ ជាចុងក្រោយ បន្ទាប់ពី៨៥នាទីក្រោយមក ក្រេក អេតឆេសាន់ ត្រូវបានផ្ដល់ឱកាសឲ្យឆ្លើយនឹងសំណួរ។ រូបខ្ញុំផ្ទាល់បានដឹងពីអ្នកនិយាយភាសាខ្មែរពីកំណើតថាឯកសារខ្មែរក្រហមជាច្រើនពិតជាលំបាកយល់ ពីព្រោះថាឯកសារទាំងនោះស្ទើរតែទាំងអស់ត្រូវបានសរសេរជាអក្សរកាត់ ដែលភាគច្រើនប្រធាន និងកិរិយាស័ព្ទត្រូវបានលុបចោល។ បើទោះបីជាផលវិបាករបស់ការបកស្រាយនិងការបកប្រែគឺជាបញ្ហាដែលកើតឡើងនិងទទួលស្គាល់ជាទូទៅនៅក្នុងអង្គជំនុំជម្រះនេះក៏ដោយ ក៏បញ្ហាទាំងនេះបានស៊ីពេល និងការខិតខំប្រឹងប្រែងយ៉ាងច្រើន។

ប៉ុន្មាននាទីបន្ទាប់ពីបញ្ហាបកប្រែត្រូវបានស្ងប់ស្ងាត់ទៅ ជម្លោះនីតិវិធីមួយផ្សេងទៀតបានចាប់ផ្ដើមកើតមានឡើង។ សហព្រះរាជអាជ្ញា អាឡិចសាន់ឌ្រឺ បេ៊ត បានព្យាយាមសួរទៅកាន់ ក្រេក អេតឆេសាន់ ទាក់ទិននឹងសំបុត្រចំនួន៩ច្បាប់ផ្ញើរពីកងពល៥០២ ដោយអនុលេខា ស៊ូ ម៉េត ទៅឲ្យ ឌុច និយាយពីជនក្បត់ដែលជឿថាត្រូវបានចាប់ខ្លួនពីកងពល៥០២ បញ្ជូនមកកាន់មន្ទីរស-២១។ ហ្វ្រង់ស៊័រ រូ បានបដិសេធចំពោះការប្រើប្រាស់សំបុត្រចំនួន៦ច្បាប់ក្នុងចំណោមសំបុត្រទាំង៩ច្បាប់នោះ ដែលមិនត្រូវបានដកស្រង់ចេញពីរបាយការណ៍ដ៏ជំនាញរបស់ ក្រេក អេតឆេសាន់។ ដោយធ្វើការលើកឡើងពីមតិយោបល់របស់លោកដែលនិយាយកាលពីថ្ងៃព្រហស្បតិ៍ មុនសារជាថ្មីម្ដងទៀត ហ្វ្រង់ស៊័រ រូ បានអះអាងថា ដោយសារតែទំនាក់ទំនងរួមគ្នារបស់លោកជាមួយនឹងការិយាល័យសហព្រះរាជអាជ្ញា និង

ការចូលរួមក្នុងដំណើរការស៊ើបអង្កេតសំណុំរឿងនេះ ក្រេក អេតឆេសាន់ មិនគួរត្រូវបានអនុញ្ញាតឲ្យបញ្ចេញមតិយោបល់លើព័ត៌មានដែលលោកបានយល់ដឹងច្បាស់ក្រោយពីខែកក្កដា ឆ្នាំ២០០៧ ជាពេលដែលលោកបានប្រគល់របាយការណ៍ដ៏ជំនាញរបស់លោកនោះទេ ។ ហ្វ្រង់ស៊័រ រូ បានទទូចសុំឲ្យមានការសម្រេចនូវ«ការព្រមព្រៀងគ្នាដ៏សមរម្យមួយ»ទាក់ទិននឹងបញ្ហានេះ ក្នុងអំឡុងពេលបិទអង្គជំនុំជម្រះកាលពីថ្ងៃព្រហស្បតិ៍មុន ប៉ុន្តែគ្មាននរណាម្នាក់យល់ស្របជាមួយនឹងលោកឡើយ ។ សហព្រះរាជអាជ្ញា អាឡិចសាន់ឌ្រី បើត បានគូសបញ្ជាក់ថាតុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀតអនុញ្ញាតឲ្យសាក្សីចំណាយប្រាក់ ឬដួលភាគីមួយឲ្យធ្វើកសិណសាក្សីបាន ។

បន្ទាប់ពីការសម្រាកមួយរយៈពេលមក ចៅក្រម ឡាវែន់ បានសួរបញ្ជាក់ថា តើ ហ្វ្រង់ស៊័រ រូ នឹងអនុញ្ញាតឲ្យមានការចោទសួរទៅកាន់ ក្រេក អេតឆេសាន់ ទាក់ទិននឹងព័ត៌មានក្រោយពីខែកក្កដា ឆ្នាំ ២០០៧ដែរឬទេ ប្រសិនបើចៅក្រមបានយល់ស្របគ្នាធ្វើការត្រួតពិនិត្យលើចម្លើយរបស់លោកដោយ «ភាពមិនជឿជាក់ទាំងស្រុង» ដោយសារតែទំនាក់ទំនងជាផ្លូវការរបស់លោកជាមួយនឹងព្រះរាជអាជ្ញា ។ ហ្វ្រង់ស៊័រ រូ បាននិយាយថា លោកសូមយល់ស្របជាមួយនឹងដំណោះស្រាយដោយ«ភាពមិនជឿជាក់ទាំងស្រុង»នេះ ប៉ុន្តែការពិភាក្សាវែកញែកនៅតែកើតឡើងបន្តទៀត ហើយក្រោយមកចៅក្រមក៏បានផ្អាកដំណើរការតុលាការសម្រាប់ថ្ងៃនេះ មុននឹងធ្វើការសម្រេចលើបញ្ហានេះ ។

ក្រេក អេតឆេសាន់ នឹងត្រូវចូលមកបង្ហាញខ្លួននៅក្នុងបន្ទប់សវនាការសារជាថ្មីម្តងទៀតនៅថ្ងៃស្អែក ។ សង្ឃឹមថា លោកនឹងអាចជំនះនឹងបញ្ហានៅក្នុងថ្ងៃនេះទាក់ទិននឹងសំណួរមួយដែលត្រូវបានឆ្លើយក្នុងរយៈពេលដល់ទៅមួយម៉ោងកន្លះនេះបាន ។